**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តតាកែវ**
សំណុំរឿងរដ្ឋប្បវេណីលេខ: ២០៩
ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤
**សាលក្រមលេខ: ២១"ឆ"**
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តតាកែវ

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០២៤ លើសំណុំរឿងរដ្ឋប្បវេណីលេខ:២០៩ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៤ នៅសាលាដំបូងខេត្តតាកែវ ដោយមានសមាសភាព:

## ចៅក្រមជំនុំជម្រះ

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តតាកែវ

## ក្រឡាបញ្ជី

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តតាកែវ

-ដើមចោទ ធនាគារ[redacted]សាខាស្រុកអង្គរបូរី-ឃុំអង្គរបូរី មានទីស្នាក់ការនៅក្បាលដី [redacted]។ លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ។

**-សហចុងចម្លើយ:**

ឈ្មោះ [redacted] ម៉េន ភេទស្រី កើតថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៨៥ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ [redacted]

ឈ្មោះ [redacted]តូ ភេទប្រុស កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៧ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ[redacted]

ឈ្មោះ [redacted] គី ភេទស្រី កើតថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៩៩ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ[redacted]



Scanned with CamScanner

## សេចក្តីសង្ខេបនៃរឿងក្តី

**កម្មវត្ថុបណ្តឹង:** ដើមចោទប្តឹងសុំតុលាការចេញសាលក្រម:

១-យោងតាមកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២៖

១.១-បង្គាប់ឱ្យសហចុងចម្លើយ សងប្រាក់ដើមចំនួន USD ២៣,១២៤.៧៥(ម្ភៃបីពាន់មួយរយម្ភៃបួន និងចិតសិបប្រាំសេន ដុល្លារអាមេរិកគត់) មកឱ្យដើមចោទ ។

**១.២**-បង្គាប់ឱ្យសហចុងចម្លើយសងការប្រាក់ ដែលស្មើនឹងប្រាក់ដើមចំនួន USD ២៣,១២៤.៧៥(ម្ភៃបីពាន់មួយរយម្ភៃបួន និងចិតសិបប្រាំសេន ដុល្លារអាមេរិកគត់) គុណនឹងអត្រាការប្រាក់១,០៥%(ក្នុងមួយខែ) គុណនឹង រយៈពេលដែលយឺតចាប់ពីខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួន មកឱ្យដើមចោទ ។

១.៣-បង្គាប់ឱ្យសហចុងចម្លើយសងប្រាក់ពិន័យ ដែលស្មើនឹងប្រាក់ដើមចំនួន USD ២៣,១២៤.៧៥(ម្ភៃបីពាន់មួយរយម្ភៃបួន និងចិតសិបប្រាំសេន ដុល្លារអាមេរិកគត់)គុណ នឹងអត្រា ២៧%(ក្នុងមួយឆ្នាំ) គុណនឹងរយៈពេលដែលយឺតចាប់ពីខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួនមកឱ្យដើមចោទ ។

**២**-បង្គាប់ឱ្យសហចុងចម្លើយសងការខាតបង់ពេលវេលា សំណងជម្ងឺចិត្ត និងចំណាយសេវាផ្លូវច្បាប់ ចំនួន ២០.០០០.០០០៛(ម្ភៃលានរៀលគត់) ឱ្យមកដើមចោទ។

៣-ប្រាក់ប្រដាប់ក្តីទាំងអស់ជាបន្ទុករបស់សហចុងចម្លើយ។

៤-ស្នើសុំឱ្យតុលាការប្រកាសថា សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន ។

## អង្គហេតុ និងចំណុចវិវាទ

### ក. ការពន្យល់ត្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ សហចុងចម្លើយឈ្មោះ [redacted] **ម៉េន** ភេទស្រី កើតថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៨៥ ,ឈ្មោះ [redacted] **ត្ង** ភេទប្រុស កើតថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៧ និងឈ្មោះ [redacted] **តី** ភេទស្រី កើតថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៩៩ បានចុះកិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ ជាមួយដើមចោទ ក្នុងការខ្ចីប្រាក់កម្ចីចំនួនUSD**២៥.០០០.០០**(ម្ភៃប្រាំពាន់ដុល្លារអាមេរិកគត់) ដោយបានសន្យាគោរព និងអនុវត្តរាល់កាតព្វកិច្ចទាំងអស់តាមកិច្ចសន្យា។ បន្ទាប់ពីទទួលបានប្រាក់កម្ចីពី [redacted] សាខាស្រុកអង្គរបូរី-ឃុំអង្គរបូរី រួមមក សហចុងចម្លើយមិនទាន់បានបង់សងប្រាក់អស់នៅឡើយទេ គឺនៅជំពាក់ប្រាក់ដើមដូចខាងក្រោម៖

-កិច្ចសន្យាខ្ចីបរិភោគដោយភ្ជាប់ការប្រាក់ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ គឺនៅជំពាក់ប្រាក់ដើមចំនួន USD ២៣,១២៤.៧៥(ម្ភៃបីពាន់មួយរយម្ភៃបួន និងចិតសិបប្រាំសេនដុល្លារអាមេរិកគត់) ហើយសហចុងចម្លើយបានឈប់បង់សងប្រាក់កម្ចី ចាប់ពីខែកញ្ញា ឆ្នាំ២០២៣ រហូតមកដល់ពេលបច្ចុប្បន្ន។ ដោយខាងដើមចោទ បានព្យាយាមដោះស្រាយជាមួយសហចុងចម្លើយជាច្រើនលើក



Scanned with CamScanner

ដើមចោទ ព្រោះខ្លួនពុំមានលទ្ធភាពបង់ទេ ដោយមូលហេតុ ថាសព្វថ្ងៃនេះ ខ្លួនរកចំណូលមិនបាន។ គប្បីតុលាការទទួលមកពិចារណា។

**៥**-តាមកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ការអះអាងដោយអ្នកតំណាងដោយអាណត្តិឱ្យដើមចោទ និងការអះអាងរបស់សហចុងចម្លើយឱ្យតុលាការជឿងជាក់បានថាសហចុងចម្លើយពិតជាមានកំហុសក្នុងការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនក្នុងការបង់ប្រាក់ឱ្យដើមចោទ។

**៦**-តាមការអះអាងរបស់អ្នកតំណាងដោយអាណត្តិឱ្យដើមចោទ ការមិនអនុវត្តកាតព្វកិច្ចរបស់សហចុងចម្លើយបានធ្វើដើមចោទខាងបង់ពេលវេលា សំណងជម្ងឺចិត្ត និងការចំណាយលើសេវាកម្មផ្លូវច្បាប់ ចំនួន ២០.០០០.០០០ (ម្ភៃលានរៀល) ខ្លួននៅតែរក្សាការទាមទារ និងសូមឱ្យតុលាការមេត្តាពិចារណាតាមស្ថានភាពជាក់ស្តែង។ គប្បីតុលាការលើកមកពិចារណា។

**៧**-ចំពោះសាលក្រម អ្នកតំណាងឱ្យដើមចោទបានស្នើសុំឱ្យតុលាការប្រកាសពីអានុភាពអនុវត្តជាបណ្តោះអាសន្ន។ តាមការពិនិត្យភស្តុតាងជាឯកសារ ក៏ដូចជាការអះអាងរបស់អ្នកតំណាងរបស់ដើមចោទ ដែលមានភាពត្រូវគ្នានឹងការអះអាងសហចុងចម្លើយ តុលាការយល់ឃើញថា ពិតជាមានអត្ថិភាពនៃសិទ្ធិលើបំណុល ដែលសហចុងចម្លើយបានជំពាក់ប្រាក់របស់ដើមចោទប្រាកដមែន។ គប្បីតុលាការសម្រេចឱ្យអនុវត្តជាបណ្តោះអាសន្នតាមបញ្ញត្តិមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៨-ដើមចោទទាមទារឱ្យសហចុងចម្លើយទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី នីតិវិធីដែលបានបង់រួច គប្បីតុលាការសម្រេចអនុវត្តតាមមាត្រា៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១/- បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ែន ,ឈ្មោះ [redacted] តូ និងឈ្មោះ [redacted] តី រួមគ្នាសងប្រាក់ដើមចំនួន USD ២៣,១២៤.៧៥(ម្ភៃបីពាន់មួយរយម្ភៃបួន និងចិតសិបប្រាំសេន ដុល្លារអាមេរិក) ឱ្យដើមចោទ។

២/- បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ែន ,ឈ្មោះ [redacted] តូ និងឈ្មោះ [redacted] តី រួមគ្នាបង់ការប្រាក់ ដែលស្មើនឹងប្រាក់ដើមចំនួន USD ២៣,១២៤.៧៥(ម្ភៃបីពាន់មួយរយម្ភៃបួន និងចិតសិបប្រាំសេន ដុល្លារអាមេរិក) គុណនឹងអត្រាការ ១,០៥%(ក្នុងមួយខែ) គុណនឹង រយៈពេលដែលយឺតចាប់ពីខែកញ្ញា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់គ្រប់ចំនួនមកឱ្យដើមចោទ ។

៣/- បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ម៉ែន ,ឈ្មោះ [redacted] តូ និងឈ្មោះ [redacted] តី រួមគ្នាបង់ប្រាក់ពិន័យ ដែលស្មើនឹងប្រាក់ដើម ចំនួន USD ២៣,១២៤.៧៥(ម្ភៃបីពាន់មួយរយម្ភៃបួន និងចិតសិបប្រាំសេន ដុល្លារអាមេរិក)គុណនឹងអត្រា ចំនួន ២៧% (ម្ភៃប្រាំពីរភាគរយ) ក្នុងមួយឆ្នាំ គុណនឹងរយៈពេលដែលយឺតចាប់ពីខែកញ្ញា ឆ្នាំ២០២៣ រហូតដល់សងគ្រប់ចំនួនឱ្យដើមចោទ ។



Scanned with CamScanner

៤/- បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ,ឈ្មោះ [redacted] និងឈ្មោះ [redacted] គឺ រួមគ្នា បង់ប្រាក់ថ្លៃសេវាកម្មច្បាប់ចំនួន ៤.000.000 (បួនលានរៀល) ឱ្យដើមចោទ។ ច្រានចោលការទាមទារលើសពីនេះ។

៥/-សាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះអាសន្ន នៃសេចក្តីសម្រេចត្រង់ចំណុចទី១។

៦/-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

សាលក្រមនេះ គូភាគីអាចប្តឹងឧទ្ធរណ៍តាមបញ្ញត្តិមាត្រា២៦០ និងមាត្រា២៦៤ នៃក្រមនីតិវិធី-រដ្ឋប្បវេណី។

ថ្ងៃព្រហស្បតិ៍ ៥រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

តាកែវ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

**ចៅក្រម**

**(ហត្ថលេខា និងត្រា)** [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃព្រហស្បតិ៍ ៥រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

តាកែវ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រម**

[redacted]



Scanned with CamScanner